ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Aug-2022, 10:40
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

នៅចំពោះមុខ៖

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម** Chandra Nihal JAYASINGHE
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម** Florence Ndepele Mwachande MUMBA
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម** Maureen Harding CLARK
**ចៅក្រម យ៉ា ណារិន**

| | |
|---|---|
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២២ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | **សាធារណៈ** |

---

# ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលដីកា

---

**សហព្រះរាជអាជ្ញា**

ជា លាង

Fergal GAYNOR (បម្រុង)

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Megan HIRST

**ជនជាប់ចោទ**

ខៀវ សំផន

**មេធាវីការពារក្តី**

គង់ សំអុន

Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" "អង្គជំនុំជម្រះ" និង"អ.វ.ត.ក.")

**កត់សម្គាល់ឃើញ**ថា នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមរបស់ខ្លួន និងទោសក្នុងសំណុំរឿង ០០២/០២ តាមរយៈការចេញសេចក្ដីសង្ខេបដោយផ្ទាល់នៃការយល់ឃើញ និងផ្នែកសម្រេចសេចក្ដីនៃសាលក្រមនោះ និងក្រោយមកបានជូនដំណឹងភាគីនូវសាលក្រមជាលាយលក្ខណ៍អក្សរនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ជាភាសាខ្មែរ បារាំង និង អង់គ្លេស ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")[1]

**បានទទួល**បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា[2] និង ខៀវ សំផន[3] ព្រមទាំងសារណាតបរបស់ភាគីនីមួយៗ[4]

**រំលឹក**ថា ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានប្រកាសនៅពេលបញ្ចប់សវនាការបណ្ដឹងសាទុក្ខនៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ថា អង្គជំនុំជម្រះនឹងជូនដំណឹងអំពីកាលបរិច្ឆេទនៃការប្រកាសសាលដីកាក្នុងពេលសមស្រប[5]

**ស្របតាម**វិធាន ១០៤ ស្ទួន ៩៨(១) ១០២(១) នៃវិធានផ្ទៃក្នុង

---

[1] ការប្រកាសសាលក្រមសំណុំរឿង ០០២/០២ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1។ សាលក្រមសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465។

[2] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F50។

[3] បណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54។

[4] សារណាតបរបស់មេធាវីការពារក្ដី ខៀវ សំផន ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F50/1។ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ ឯកសារលេខ F54/1។ សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ ឯកសារលេខ F54/2។

[5] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១ ឯកសារលេខ ទំព័រ ៦១-៦២។

**អាស្រ័យហេតុនេះ៖**

**ជូនដំណឹង**ភាគីថា សាលដីកាក្នុងសំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ពាក់ព័ន្ធទៅនឹងជនជាប់ចោទ ខៀវ សំផន នឹងត្រូវប្រកាសនៅថ្ងៃ ព្រហស្បតិ៍ ទី ២២ ខែ កញ្ញា ឆ្នាំ ២០២២ វេលាម៉ោង ០៩ និង ៣០ នាទីព្រឹក ក្នុងបន្ទប់សវនាការធំរបស់ អ.វ.ត.ក.។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**